# ការបណ្តេញចេញ (expulsion)

ការបណ្តេញចេញ គឺជាការបញ្ជូនចេញ នូវអ្នកមានលំនៅស្របច្បាប់ (lawful resident) ពីដែនដីនៃរដ្ឋដោយអាជ្ញាធររដ្ឋាភិបាល។

អនុសញ្ញា ស្តីពីឋានៈរបស់ជនភៀសខ្លួន ក៏អនុញ្ញាតឲ្យបណ្តេញនូវជនភៀសខ្លួន ប្រសិនបើបានធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខរបស់រដ្ឋផ្តល់សិទ្ធិជ្រកកោន (មាត្រា៣២)។ ការបណ្តេញនេះ ត្រូវធ្វើដោយសេចក្តីសម្រេច មានយុត្តិធម៌ និងទុកពេលឲ្យជនភៀសខ្លួន រកការសុំចូលប្រទេសផ្សេងទៀត។

ការបណ្តេញចេញ អាចកើតមានឡើង ក្នុងក្របខ័ណ្ឌនៃបទល្មើស ក្នុងគោលបំណង បំផ្លាញពូជសាសន៍ (ethnic cleansing) ឬប្រល័យពូជសាសន៍ ដូចករណីកើតមាននៅអតីតយូហ្គោស្លាវីឆ្នាំ ១៩៩០។ ករណីនេះ សំដៅលើការបណ្តេញជាទ្រង់ទ្រាយធំ នូវក្រុមសាសនា ដើម្បីទន្ទ្រានយកដីបន្តដោយសកម្មភាពសម្លាប់មនុស្ស។

ប្រវត្តិនៃការបណ្តេញចេញកើតជាយូរហៃរ ជាយូរមកហើយតាំងពីឆ្នាំ ១៣០៦ នៅបារាំង ក្នុងឆ្នាំ ១៣៤៩ នៅប្រទេសហុងគ្រី និងនៅអេស្ប៉ាញ ឆ្នាំ ១៤៩២ ហើយក្នុងទសវត្សឆ្នាំ១៨៣០ នៅសហរដ្ឋអាមេរិកជាដើម (Samuel Totten and Paul R. Bartrop, Dictionary of Genocide, Vol.1, 2008, pp.139-140)។

**ខ្លឹមសារបន្ថែម៖** អត្ថន័យផ្សេងទៀត នៃពាក្យ “បណ្តេញចេញ” សំដៅការដេញនូវជនបរទេសរស់នៅខុសច្បាប់ ដោយហួសសុពលភាពនៃទិដ្ឋាការរស់នៅ។ នេះជាការអនុវត្តច្បាប់អន្តោប្រវេសន៍។ វាក៏ជាការបណ្តេញនូវជនបរទេសរស់នៅស្របច្បាប់ តែបានប្រព្រឹត្តបទល្មើស ដែលនាំឲ្យគេចាត់ថា លែងរស់នៅស្របច្បាប់។ ការបណ្តេញក្នុងករណីចុងក្រោយនេះ អាចហាមជារហូត មិនឲ្យជនរូបនោះចូលមកជាថ្មី។